# Martus™
## ប្រព័ន្ធព្រឹត្តិបត្រ សិទ្ធិមនុស្ស

**បញ្ហា**

ព័ត៌មានមានទំនាក់ទំនងយ៉ាងសំខាន់ទៅនឹងផ្នែកសិទ្ធិមនុស្ស។ វាគឺជាទ្រព្យសម្បត្តិដ៏មានតំលៃបំផុតរបស់អង្គការសិទ្ធិមនុស្សក្រៅរដ្ឋាភិបាល ជាច្រើន ហើយ វាដើរតួជាឧបករណ៍ដ៏សំខាន់ដើម្បីប្រឆាំងនឹងការកើនឡើងយ៉ាងឆាប់រហ័សនៃអំពើហឹង្សារំលោភ សិទ្ធិមនុស្ស។ អង្គការក្រៅរដ្ឋាភិបាលប្រមូលព័ត៌មានអំពីអំពើហឹង្សាដើម្បីអោយមានការចាប់អារម្មណ៍ដល់ស្ថានភាពជនរងគ្រោះនិងនាំយកជនល្មើសមកកាត់ទោស។ នៅពេលដែលគេប្រមូលព័ត៌មាន អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិប្រើប្រាស់ ព័ត៌មានដើម្បីផ្តោតការចាប់អារម្មណ៍លើការយកចិត្តទុកដាក់ផ្នែកប្រព័ន្ធ ផ្សព្វផ្សាយ ការពង្រឹងចំណេះដឹង និង ការគាបសង្កត់ផ្នែកនយោបាយ ហើយនិងជួយផ្សព្វផ្សាយយុត្តិធម៌ក្នុងទម្រង់គណៈកម្មការ និងសាលាក្តីយុត្តិធម៌។ បើគ្មានការប្រមូល និង ការប្រើប្រាស់ព័ត៌មានបែបនេះទេ ឱកាសទទួលជោគជ័យនៃយុទ្ធនាការសិទ្ធិមនុស្សនឹងមានកម្រិត។

ទោះបីជាយ៉ាងណាក៏ដោយ អង្គការសិទ្ធិមនុស្សអន្តរជាតិ និង ក្នុងស្រុកបានប្រាប់យើងថា ភាគច្រើននៃព័ត៌មានអំពើហឹង្សា និង ការរំលោភបំពានដែលបានប្រមូលដោយក្រុមសិទ្ធិមនុស្សសាមញ្ញគឺកំពុងតែបាត់ដោយការរឹបអូស ការបំផ្លាញ ឬ ការខ្ជីខ្ជា ដែលជាការកាត់បន្ថយនូវប្រសិទ្ធភាព និង ធ្វើអោយកាន់តែលំបាក ឬ មិនអាចធ្វើទៅបានចំពោះព្រះរាជអាជ្ញា គណៈកម្មការនិងសាលាក្តីយុត្តិធម៌ក្នុងការប្រើប្រាស់ព័ត៌មានជាភស្តុតាងដើម្បីកាត់ក្តីជនល្មើសពីបទ រំលោភសិទ្ធិមនុស្សអោយសមទៅនឹងទោសកំហុស។

សហគមន៍សិទ្ធិមនុស្សបានចង្អុលបញ្ជាក់ប្រាប់យើងថាខ្លួនត្រូវការជាបន្ទាន់នូវឧបករណ៍ដើម្បីប្រមូល រៀបចំ និងរក្សាព័ត៌មានអំពីអំពើហឹង្សាសិទ្ធិមនុស្ស យ៉ាងមានសុវត្ថិភាព ដែលអនុញ្ញាតអោយពួកគេនាំយកនូវចំណាប់អារម្មណ៍កាន់តែខ្លាំងក្លាអំពីអំពើហឹង្សារំលោភសិទ្ធិមនុស្ស និង ដើម្បីជួយក្នុងការកាត់ទោសជនល្មើស និង បង្អាក់នូវ អំពើរំលោភបំពានថែមទៀត។ ឧបករណ៍នេះគួរតែៈ

- ការពារព័ត៌មានពីការបាត់បង់ ការលួច ឬ ការបំផ្លិចបំផ្លាញ។

- ធានាថាឯកសារពីក្រុមសិទ្ធិមនុស្សត្រូវបានរក្សាការពារ ដោយអនុញ្ញាតអោយអ្នកស្រាវជ្រាវទាំងអស់កាន់តែមានភាពងាយស្រួលក្នុងការប៉ាន់ប្រមាណព្រំដែន និង កម្រិតនៃអំពើហឹង្សា ហើយនិងដើម្បីសរសេរលក្ខណៈវិនិច្ឆ័យក្តីនៃអំពើរំលោភបំពានដោយ ផ្អែកលើព័ត៌មានពីសាក្សីកាន់តែច្រើនថែមទៀត។
- ផ្តល់ដល់ក្រុមជនសាមញ្ញនូវអំណាចគ្រប់គ្រងព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេ ដោយអនុញ្ញាតអោយគេសម្រេចចិត្តនូវអ្វីដែលត្រូវផ្សព្វផ្សាយជាសាធារណៈនិងអ្វីដែលគួរតែរក្សាជាការសម្ងាត់ផ្ទាល់ខ្លួន។
- អាចអោយសកម្មជន ព្រះរាជអាជ្ញា សារព័ត៌មាន និង សាធារណៈជន ចូលសាកសួរដល់ជនដែលរងគ្រោះដោយសារអំពើហឹង្សាសិទ្ធិមនុស្ស។

សមាគមន៍អាមេរិកាំងសម្រាប់ការរីកចំរើននៃវិទ្យាសាស្ត្រ ប៉ាន់ប្រមាណថាមានអង្គការសិទ្ធិមនុស្សប្រហែលជា ១០០០០ ទូទាំងពិភពលោក ដែលប្រមូលព័ត៌មានក្នុងការស្រាវជ្រាវក្នុងទម្រង់ជាច្រើន។ ការស្រាវជ្រាវ និង សម្ភាសន៍ បង្ហាញថាអង្គការទាំងនោះរក្សាទុកឯកសារ ដោយប្រើវិធីសាស្ត្រផ្សេងៗគ្នាតាំងពីការរក្សាទុកដោយដៃ ឬ កំណត់ ចំណាំដោយអង្គុលីលេខ រហូតដល់តារាងបញ្ជីដោយប្រើកុំព្យូទ័រ ជាលទ្ធផលគឺការរក្សាទុកនូវឯកសារដែល មិនជាក់លាក់ និង គ្មានរបៀប ដែលនោះគឺពិបាកក្នុងការចែកចាយព័ត៌មានក្នុងផ្នែកសិទ្ធិមនុស្ស។ ក្រៅពីនោះ ក្នុងកំឡុងពេលចុះធ្វើការស្រាវជ្រាវ អ្នកប្រើប្រាស់បានប្រាប់យើងថា ព័ត៌មានដែលពួកគេបានរក្សាទុកក្នុងកុំព្យូទ័រ ឬ ទុកជាទម្រង់ឯកសារ ងាយក្នុងការលួច បាត់បង់ ឬ ការបំផ្លិចបំផ្លាញ។ ជាឧទាហរណ៍ នៅឯអង្គការសិទ្ធិមនុស្សមួយក្នុងប្រទេសស្រីលង្កា សត្វកណ្តៀរបានស៊ីឯកសារស្តីអំពីអំពើហឹង្សាដែលគេប្រមូលទុកកាលពី៧ឆ្នាំមុនក្នុងប្រដាប់រក្សាឯកសារ។

### ដំណោះស្រាយ – កម្មវិធី Martus (ម៉ាថឹស)

ដើម្បីដោះស្រាយបញ្ហានេះ Benetech (បិននីថេច) ដែលជាក្រុមហ៊ុនបច្ចេកវិទ្យាមិនយកប្រាក់កំរៃនាំមុខគេផ្អែករូបធាតុសីលីកូន បានបង្កើតប្រព័ន្ធសំណុំរឿងសិទ្ធិមនុស្សនៃម៉ាថឹស ដែលជាឧបករណ៍បច្ចេកវិទ្យាបើកទូលាយដែលគេរចនាឡើង ដើម្បីជួយអង្គការសិទ្ធិមនុស្សក្នុងការប្រមូល រក្សា រៀបចំ និង ផ្សព្វផ្សាយព័ត៌មានអំពីការរំលោភសិទ្ធិមនុស្ស។  វាអាចអោយអង្គការក្រៅរដ្ឋាភិបាលសាមញ្ញរក្សាទុកឯកសាររបស់ពួកគេនៅលើម៉ាស៊ីនបម្រើដែលនៅឆ្ងាយជាមួយកម្មវិធីដែលងាយស្រួលប្រើ ដែលរក្សាការពារនូវភស្តុតាងដ៏មានសារៈសំខាន់សម្រាប់ការស្រាវជ្រាវ ការស៊ើបអង្កេត និង ការកាត់ទោស។

កម្មវិធីត្រូវបានបង្កើតឡើងដោយមានការប្រឹក្សាជាមួយក្រុមនិងអ្នកជំនាញសិទ្ធិមនុស្សទូទាំងពិភពលោក ជាពិសេសគឺលោកបណ្ឌិត Patrick Ball (ផាទ្រីក ប៊ល) ដែលជាអ្នកប្រមូលស្ថិតិស្តីពីសិទ្ធិមនុស្សនាំមុខគេតែមួយគត់ក្នុងពិភពលោក។ ក្រុម Martus (ម៉ាថឹស) បានពិភាក្សាថា បញ្ហា នេះចាំបាច់មានការចូលរួមជាមួយ អង្គការសិទ្ធិមនុស្សក្រៅរដ្ឋាភិបាលអន្តរជាតិ (International human rights organizations) ដូចជា អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ (Human Right Watch) គណៈកម្មាធិការមេធាវី សម្រាប់សិទ្ធិមនុស្ស (Lawyer's Committee for Human Rights) ស្ថាប័នសង្គមកិច្ចបើកចំហ (Open Society Institute) អង្គការសហប្រជាជាតិ (The United Nations) និង អង្គការលើកលែងទោសអន្តរជាតិ (Amnesty International ) ព្រមទាំងអង្គការសាមញ្ញមកពីគ្រប់ប្រទេសច្រើនជាង១២។ ក្រៅពីនេះ មុនពេលចាប់ផ្តើមសរសេរកម្មវិធី Benetech (បិននីថេច) បានធ្វើការស្រាវជ្រាវផ្នែកទីផ្សារ ក្នុងប្រទេស ស្រីលង្កា កម្ពុជា ហ្គាតេម៉ាឡា និង រុស្ស៊ី។ ក្រុមសិទ្ធិមនុស្សច្រើនជាង ១២ក្នុង ប្រទេស ហ្គាតេម៉ាឡា រុស្ស៊ី ស្រីលង្កា និង កំណែកម្មវិធីចេញផ្សាយពីមុនដែលត្រូវបានសាកល្បងដោយ

សហរដ្ឋអាមេរិក ផ្តល់នូវព័ត៌មានត្រឡប់យ៉ាងសំខាន់ស្តីអំពីបញ្ហារចនា និង ភាពអាចប្រើប្រាស់បានដែលនាំទៅរកការផ្លាស់ប្តូរយ៉ាងសំខាន់នៅកំណែចុងបញ្ចប់។ អ្នកសាកល្បងនិងអ្នកគាំទ្រដ៏ច្រើនលើសលប់ រួមបញ្ចូលទាំង គណៈកម្មការសិទ្ធិមនុស្សនៃប្រទេស ស្រីលង្កា សហគមន៍ទីភ្នាក់ងារមនុស្សធម៌នៃប្រទេស ស្រីលង្កា Centro para Accion Legal en Derechos Humanos (មជ្ឈមណ្ឌលសម្រាប់ អំពើស្របច្បាប់ នៃ សិទ្ធិមនុស្ស)នៅក្នុងប្រទេស ហ្គាតេម៉ាឡា និង ក្រុមជាច្រើនផ្សេងទៀត។

ជាលទ្ធផល ប្រព័ន្ធឯកសារសិទ្ធិមនុស្សនៃម៉ាថឹសបានលើកឡើងនូវអ្វីដែលអ្នកប្រើប្រាស់បានប្រាប់យើងគឺជាតំរូវការយ៉ាងសំខាន់បួនសម្រាប់កម្មវិធីដែលការពារឯកសាររបស់ក្រុមសិទ្ធិមនុស្សសាមញ្ញ៖

- **អាចប្រើប្រាស់បាន** កម្មវិធីគឺងាយប្រើប្រាស់ដូចជាអ៊ីម៉ែល អាចដំណើរការបាននៅលើកុំព្យូទ័រមិនថ្លៃពេក ហើយមិនត្រូវការភ្ជាប់ទៅអ៊ិនធឺណែតជាប់រហូត។
- **សុវត្ថិភាព** ឯកសារត្រូវបានបម្លែងជារហស្សលិខ ត្រូវបានរក្សាទុកយ៉ាងមានសុវត្ថិភាពនៅតំបន់ឆ្ងាយ ចម្លងទុកច្រើនកន្លែង និង ការពារដោយពាក្យសំងាត់តែមួយគត់។
- **អាចរកឃើញ** បទល្មើសដ៏ច្បាស់លាស់ និង ភាពពិស្តារដែលអាចកំណត់សម្គាល់បាន អាចត្រូវបានគេរកឃើញក្រុមមនុស្ស ឬ ក្រុមអ្នកស្រាវជ្រាវដែលបានទទួលសិទ្ធិចូលទៅកាន់ឯកសារ។
- **មានតម្លាភាព** កម្មវិធីគឺបើកទូលាយនូវពាក្យសំងាត់ ក្រុមណាក៏អាចពិនិត្យមើលពាក្យសំងាត់ ហើយនិងធ្វើការសំរេចចិត្តយ៉ាងជាក់ច្បាស់អំពីការប្រើប្រាស់កម្មវិធីម៉ាថឹស។

ការអនុម័តនិងការដាក់ពង្រាយនៃបច្ចេកវិទ្យានេះនឹងជួយធានាអះអាងថាឯកសារនៃអំពើរំលោភបំពានសិទ្ធិមនុស្សត្រូវបានការពារ និង ងាយស្រួលក្នុងការចូលដំណើរការ។

កម្មវិធីម៉ាថឹសនាពេលអនាគតរួមបញ្ចូលនិងការពិនិត្យបញ្ហាផ្សេងទៀតដូចជា អំពើហឹង្សាប្រឆាំងស្ត្រី ការជួញដូរមនុស្ស ការបំផ្លាញបរិដ្ឋាន និងការស្អប់ឧក្រិដ្ឋកម្ម។កម្មវិធីនិងអក្សរសំងាត់របស់វាអាចរកបាន និង ថតចំលងចូលម៉ាស៊ីនតាមរយៈ www.martus.org ។